PTI0057

# សម្ភាសន៍ជាមួយឈ្មោះ ជា ភាន ហៅ ញ៉ាន ភេទប្រុស អាយុ៥៤ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“យោធា”

ស្រុកកំណើតនៅភូមិព្រែកតាកែ ឃុំល្វា ស្រុកកោះសូទិន ខេត្តកំពង់ចាម

រស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២០ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៨:២៤

៣១ទំព័រ

វណ្ណៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២០ខែ៥ឆ្នាំ២០០១ ។

ភានៈ បាទ ។

វណ្ណៈ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាណាពូ ។

ភានៈ បាទ ។

វណ្ណៈ ខ្ញុំមកភូមិឃុំពីនេះគឺចង់ដឹងរឿងរ៉ាវដែលបងប្អូនយើងធ្លាប់ឆ្លងកាត់ ក្នុងសម័យខ្មែរក្រហមក្នុងសម័យតស៊ូកាលជំនាន់លន់ នល់អីចឹងណាពូ ។

ភានៈ បាទ ។

វណ្ណៈ ថ្ងៃក្រោយមកយើងត្រូវរៃជាមួយយួនអីយ៉ាងម៉េចជួបបញ្ហាយ៉ាងម៉េចហើយខ្ញុំចង់ក្រងឯកសារទាំងអស់ហ្នឹងទុកឲ្យក្មេងជំនាន់ក្រោយបានដឹងត្រូ ។

ភានៈ បាទ ។

វណ្ណៈ ចឹងបទសម្ភាសន៍ខ្ញុំជាមួយពូហ្នឹងតើពូអនុញ្ញាតឲ្យខ្ញុំសរសេរទុកឲ្យក្មេងៗជំនាន់ក្រោយបានទេ?

ភានៈ ចុះអាហ្នឹងមានអីមកសម្ភាសចឹងឲ្យគាត់សរសេរខ្លះៗទៅ ។

វណ្ណៈ បាទ ។

ភានៈ ជាការពិតដែលខ្ញុំនិយាយដែលខ្ញុំធ្លាប់ឆ្លងកាត់ហ្នឹង ចេញពីផ្ទះមកណាស់ ។

វណ្ណៈ បាទ!ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ?

ភានៈ ខ្ញុំចេញពីផ្ទះមកឈ្មោះ ឥឡូវដាក់ឈ្មោះឥឡូវបណ្ដោយទៅ ។

វណ្ណៈ បាទ!ចឹងឈ្មោះ ឥឡូវឈ្មោះអីគេ?

ភានៈ ឈ្មោះ ជា ភាន ។

វណ្ណៈ ជា ភាន?

ភានៈ បាទ ។

វណ្ណៈ ចឹងហៅឈ្មោះមួយទៀតហៅឈ្មោះអីទៅ?

ភានៈ ខ្ញុំឈ្មោះ ញ៉ាន ពីដើមឡើងញ៉ាន ។

វណ្ណៈ ពូអាយុប៉ុន្មានហើយរាល់ថ្ងៃ?

ភានៈ ខ្ញុំអាយុ៥៨ ។

វណ្ណៈ ចឹងប្រពន្ធពូឈ្មោះអីដែរ?

ភានៈ ហ ភឿន ។

វណ្ណៈ គាត់អាយុប៉ុន្មានដែរ?

ភានៈ គាត់អាយុ៤៨ ។

វណ្ណៈ ពូមានកូនចៅប៉ុន្មាននាក់កូនចៅ?

ភានៈ កូនចៅមាន៥នាក់បែកមួយហើយ ។

វណ្ណៈ ចឹងមានកូន៥នាក់?

ភានៈ បាទ ។

វណ្ណៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ភានៈ ស្រីមួយប្រុសបួន ។

វណ្ណៈ ចឹងឪពុកពូឈ្មោះអីដែរ?

ភានៈ ឪពុកខ្ញុំស្លាប់ហើយហ្នឹង ។

វណ្ណៈ បាទ!តែគាត់ឈ្មោះអីទៅ?

ភានៈ គាត់ឈ្មោះ ជា ភឿន ។

វណ្ណៈ ស្លាប់សម័យណាទៅ?

ភានៈ គាត់ស្លាប់ប៉ុន្មានទេ ។

វណ្ណៈ គាត់ស្លាប់ក្រោយ៧៩?

ភានៈ អត់ទេ មិនមែនក្រោយ៧៩ទេ យើងត្រូវរវូវគ្នាហើយមួយសារទៀតហ្នឹង៩០ប៉ុន្មានទេ ៩៧ ប្រពន្ធថា“៩៣” ។

វណ្ណៈ ចឹងម្តាយឈ្មោះ?

ភានៈ ម្តាយឈ្មោះ សុខ សុំ ។

វណ្ណៈ ចឹងគាត់នៅរស់ដែលរាល់ថ្ងៃ?

ភានៈ គាត់នៅ ។

វណ្ណៈ ចឹងបងប្អូនបង្កើតពូមានប៉ុន្មាននាក់?

ភានៈ បងប្អូនបង្កើតមាន៩ នាក់ ។

វណ្ណៈ នៅសល់ប៉ុន្មានសព្វថ្ងៃ?

ភានៈ នៅសស់សព្វថ្ងៃបីនាក់ ។

វណ្ណៈ ចឹងកាលពីតូចពីរៀនសូត្របានត្រឹមណាដែរ?

ភានៈ កាលពីតូចខ្ញុំរៀនបានថ្នាក់ទី៧ហ្នឹង ។

វណ្ណៈ ចឹងរៀនបានទី៧ "ចាស់" ?

ភានៈ បាទ ។

វណ្ណៈ ទី៧ចាស់ច្រើនដែលតើកាលហ្នឹង?

ភានៈ ទើបចូលបានបន្តិចហ្នឹងព្រោះយើងនេះដែលនោះ ។

វណ្ណៈ ចឹងពូមានចាំទេ កាលពូចូលរៀនពូរៀននៅឆ្នាំណា?

ភានៈ ខ្ញុំមិនដឹងជាឆ្នាំប៉ុន្មានទេនេះ ភ្លេចបាត់ហើយ ។

វណ្ណៈ ចឹងរៀនថ្នាក់ទី៧ចាស់ហ្នឹងពូរៀននៅសាលាណា?

ភានៈ បើនិយាយរឿងសាលាអត់មានសាលាជាប់លាប់ព្រោះអី ម្ដាយឪពុកគាត់ចេះតែផ្លាស់ទីលំនៅ ទៅនេះទៅនោះ ។

វណ្ណៈ បាទ ។

ភានៈ ជួនកាលនៅទៅនៅមេមុត ដល់ចឹងសាលាមិនពិតប្រាកដ ។

វណ្ណៈ បាទ!ចឹងខ្ញុំចង់ដឹងពីស្រុកកំណើតតែម្ដង ស្រុកកំណើតពូនៅភូមិអី?

ភានៈ នៅភូមិព្រែកតាកែ ឃុំល្វា ស្រុកកោះសូទិន ។

វណ្ណៈ ចឹងខេត្តកំពង់ចាមពូណឹស?

ភានៈ បាទ ។

វណ្ណៈ ចឹងឥឡូវពូរស់នៅភូមិអីឥឡូវនេះ?

ភានៈ ឥឡូវនេះ ។

វណ្ណៈ បាទ ។

ភានៈ ឥឡូវស៊ឹងថ្មី ។

វណ្ណៈ ចឹងភូមិស៊ីងថ្មី?

ភានៈ បាទ!ឃុំប្រម៉ោយ ។

វណ្ណៈ ស្រុកវាលវែង ខេត្តពោធិ៍សាត់ណាពូ?

ភានៈ បាទ ។

វណ្ណៈ ពូសព្វថ្ងៃប្រកបមុខរបរអីដែរ?

ភានៈ ខ្ញុំអត់មានធ្វើអីទេ ធ្វើតែចំការប្រពន្ធនិងបង្រៀនក្មេង ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យពូរៀបរាប់កាលពូរៀនត្រឹមថ្នាក់ទី៧យ៉ាងម៉េចបានជាពូឈប់រៀន ដោយសារមានបញ្ហាអីកើតឡើងសម័យរដ្ឋប្រហារមួយក៏យ៉ាងម៉េចពូ?

ភានៈ ជំនាន់ហ្នឹងយើងរដ្ឋប្រហាឈប់រៀនបណ្តោយ ។

វណ្ណៈ រដ្ឋប្រហាឆ្នាំ៧០?

ភានៈ បាទ!ឆ្នាំ៧០ ។

វណ្ណៈ ឈប់រៀនពូចូលធ្វើអីទៀត?

ភានៈ ខ្ញុំឈប់រៀននៅផ្លូវជាតិលេខ៧ កន្លែងគេហៅភូមិស៊ីងអីស្រុកស្ងួងនោះ ។

វណ្ណៈ បាទ ។

ភានៈ ដល់ពេលចឹងលែងយើងមានរដ្ឋប្រហាហ្នឹងមកស្រុកកំណើតនៅភូមិព្រែកតាកែហ្នឹងវិញ ។

វណ្ណៈ បាទ ។

ភានៈ មកនៅហ្នឹងមកខ្ញុំមកនៅបានជាកន្លះឆ្នាំខ្ញុំបួស ។

វណ្ណៈ ចឹងពូបួសទៀត?

ភានៈ បាទ!បួសរហូតដល់ឆ្នាំ៧៥ហ្នឹងបណ្តោយ ។

វណ្ណៈ បួសដល់ឆ្នាំ៧៥ ខ្មែរក្រហមឲ្យសឹក?

ភានៈ បាទ!ខ្មែរក្រហមឲ្យសឹក ក្រោយមកធ្វើកងចល័តបានប្រហែលជាប៉ុន្មានខែគេជ្រើសរើសឈ្មោះឡើងមកភ្នំពេញបណ្តោយ ។

វណ្ណៈ ប្រហែលជាប៉ុន្មានខែពូដឹងទេ អត់ដល់មួយឆ្នាំទេ?

ភានៈ មើលយើងសឹកខែ៥ ។

វណ្ណៈ បាទ ។

ភានៈ យើងបែកខែ៤ សឹកខែ៥ ខែ១០ខ្ញុំចេញមកភ្នំពេញ ។

វណ្ណៈ កងចល័តនៅក្នុងភូមិ?

ភានៈ	កងចល័តនៅក្នុងភូមិហ្នឹងបណ្តោយ គេថាឲ្យចូលទៅជួយធ្វើស្រែធ្វើចំការដកស្ទូងជីកព្រែកជីកប្រឡាយចឹងទៅណាស់ ។

វណ្ណៈ	ចឹងខែ១០ឆ្នាំ១៩៧៥ហ្នឹងមកភ្នំពេញហើយ?

ភានៈ	បាទ ។

វណ្ណៈ	មកភ្នំពេញគេឲ្យពូមកធ្វើអីហើយមុនហ្នឹងមកពីណាទៅជ្រើសរើសពូ គេមានប្រាប់ថាម៉េចទេ?

ភានៈ	អត់ទេ គេថាជ្រើសរើសទៅធ្វើកម្មករធ្វើការរោងចក្រនៅភ្នំពេញ ។

វណ្ណៈ	បាទ!ហ្នឹងពីណាជាអ្នកនិយាយប្រាប់ពូ?

ភានៈ	កាលហ្នឹងខាងភូមិខាងឃុំយើងហ្នឹងក្នុងស្រុកហ្នឹងគេហៅអង្គការហ្នឹងជំនាន់ហ្នឹងណាស់ ។

វណ្ណៈ	អ្នកដែលប្រាប់ពូមានស្គាល់ឈ្មោះទេ?

ភានៈ	ភ្លេចបាត់ហើយយូរហើយ ។

វណ្ណៈ	ចឹងពូដឹងថាខាងអង្គការខាងភូមិឃុំហ្នឹងប្រាប់ថា ជ្រើសរើសបងប្អូនមួយចំនួននៅតាមកងចល័តហ្នឹងមកធ្វើការនៅភ្នំពេញ?

ភានៈ	បាទ ។

វណ្ណៈ	ចឹងពេលពូថាមកភ្នំពេញពូសប្បាយទេកាលហ្នឹង?

ភានៈ	ទេ ដូចជាអត់មានទឹកឃើញថាសប្បាយយ៉ាងម៉េចទេ មានដឹងថាគេយកទៅធ្វើអីដងព្រុគេថាចូលធ្វើការនៅភ្នំពេញ កាលហ្នឹងយើងស្ម័គ្រចិត្ត ។

វណ្ណៈ	បាទ ។

ភានៈ	មួយភូមិហ្នឹងមានពីរនាក់បីនាក់គេជ្រើសរើស ។

វណ្ណៈ	បាទ ។

ភានៈ	មួយឃុំមាន៥ ទៅ៦ នាក់ចឹងមក ។

វណ្ណៈ	បាទ ។

ភានៈ	អត់មានទឹកឃើញថាសប្បាយមកភ្នំពេញយ៉ាងម៉េច បើមនុស្សមិនដែលស្គាល់ភ្នំពេញផង ។

វណ្ណៈ	ចឹងមុនហ្នឹងមកហ្នឹងយើងមានបានជំរាបទៅឪពុកម្តាយយើងវិញទេ ថាអង្គការឲ្យមកភ្នំពេញពូមានបានប្រាប់ទេ?

ភានៈ	អត់មានបានប្រាប់ទេ ។

វណ្ណៈ	ចឹងអត់មានបានផ្តែផ្តាំទេ?

ភានៈ	បាទ!អត់មានបានផ្តែផ្តាំទេ គាត់ថាឲ្យយើងមកសិនចឹងទៅកាលហ្នឹងគេប្រើអង្គការ ។

វណ្ណៈ បាទ ។

ភានៈ យើងធ្វើការបំរើអង្គការ នៅតាមអង្គភាពចឹងទៅក៏មកម៉ែឪគាត់ជាអ្នកលះបង់ណាស់ ។

វណ្ណៈ បាទ ។

ភានៈ ព្រោះមកបំរើការងារអង្គការហ្នឹង ។

វណ្ណៈ ចឹងកាលសម័យខ្មែរក្រហមហ្នឹងបងប្អូនពូចូលប៉ុន្មាននាក់ឬមួយចូលតែពូមួយទេ?

ភានៈ ជំនាន់ខ្មែរក្រហមបើបងខ្ញុំគាត់ស្លាប់ចឹងទៅគាត់ទៅមុនខ្ញុំ គាត់ចូលធ្វើការចង់និយាយថាខ្មែរក្រហមចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ភានៈ ជំនាន់៧០ហ្នឹង៧១ ។

វណ្ណៈ បងប្រុស?

ភានៈ បាទ!បងប្រុសចូលបំរើការងារអង្គការហ្នឹងមុនខ្ញុំមកបួស ។

វណ្ណៈ ៧១?

ភានៈ ចុង៧០ ដើម៧១ហ្នឹង ។

វណ្ណៈ បាទ! ឈ្មោះអីដែរ?

ភានៈ ឈ្មោះញាន ។

វណ្ណៈ ហើយសព្វថ្ងៃគាត់នៅរស់ដែរ?

ភានៈ គាត់ស្លាប់បាត់តាំងជំនាន់គេជម្លៀសចុះជម្លៀសឡើងចឹងទៅស្លាប់បាត់ហើយ ។

វណ្ណៈ គាត់ស្លាប់កាលឆ្នាំ៧៥-៧៦ឬយ៉ាងម៉េចពូ?

ភានៈ មិនមែនទេ មិនមែន៧៥ទេ ៧០ប៉ុន្មានខ្ញុំអត់ដឹងដែលនេះ ព្រោះអីខ្ញុំពូតែតាមម៉ែឪក្រោយពី៧៥មកគេមិនជម្លៀសប្រជាជនចុះឡើងមិនចឹងកាលហ្នឹង ។

វណ្ណៈ បាទ ។

ភានៈ ម៉ែឪខ្ញុំហ្នឹងគាត់ជម្លៀសចេញពីក្នុងហ្នឹងមក មកស្រុកកំណើតខ្ញុំដែលតែនៅកន្លែងចំការលើតាអុងបុសខ្នុរណាស់ ។

វណ្ណៈ បាទ ។

ភានៈ គាត់ចេញចូលទៅណាទៅណីជួបបងខ្ញុំហ្នឹងគាត់នៅធ្វើការនៅមន្ទីរអីខ្ញុំមិនដឹងទេ ។

វណ្ណៈ បាទ ។

ភានៈ ពុម្ដាយខ្ញុំនិយាយទេ រត់មកជួបគ្នាបែកគ្នាទៅវិញរៀបការអីហើយប្រពន្ធគាត់ដល់ហើយបែកគ្នាទៅបាត់ពុដំណឹងឈឹងមិនដឹងថាស្លាប់រឿងអីៗខ្ញុំមិនដឹងទេ ពុតែម៉ែខ្ញុំនិយាយណាស់ ។

វណ្ណៈ បាទ ។

ភានៈ ព្រោះខ្ញុំទើបចូលទៅស្រុក ។

វណ្ណៈ ចឹងឆ្នាំ៧៦-៧៧មានបានជួបគាត់ម្ដងអីទៀតទេ?

ភានៈ អត់មានដែលជួបអីរលីង ។

វណ្ណៈ ចឹងមានតែពីរនាក់ទេ មានពូមួយនិងបងឈ្មោះញានហ្នឹងមួយចូលបដិវត្ត?

ភានៈ បាទ ។

វណ្ណៈ ចឹងកាលពូមកធ្វើកម្មករនៅភ្នំពេញហ្នឹងពូមកធ្វើផ្នែកខាងអី ខាងអគ្គីសនីខាងក្រឡឹងឬមួយខាងអីដែរ?

ភានៈ អគ្គីសនីផ្សារតូច ។

វណ្ណៈ ខាងអគ្គីសនី?

ភានៈ បាទ ។

វណ្ណៈ ចឹងពូឥឡូវចេះអគ្គីសនីខាងភ្លើងទៀតទេ?

ភានៈ អត់ទេ ភ្លេចបាត់ហើយបើតអីតិចតួចបានដឹងតាក់ទិចដែលតើ ។

វណ្ណៈ អគ្គីសនីនៅផ្សារតូចហ្នឹងមានគ្នាប៉ុន្មាននាក់?

ភានៈ អគ្គីសនីហ្នឹងវាមានផ្នែកវា មួយខាងភ្លើងម៉ាស៊ីន មួយខាងតភ្លើងតាមផ្ទះ ។

វណ្ណៈ បាទ ។

ភានៈ បើខ្ញុំខាងបណ្ដាញជាអ្នកតភ្លើងចូលតាមរោងចក្រអីហ្នឹងណាស់ ។

វណ្ណៈ ចឹងគ្នាពូមានប៉ុន្មាននាក់ទៅខាងតភ្លើង?

ភានៈ ខាងតភ្លើងខ្ញុំភ្លេចហើយមានបីផ្នែកមួយផ្នែកមាន៣០នាក់ជាង ។

វណ្ណៈ ចឹងមានគ្នាជិត១០០នាក់ដែរ?

ភានៈ បាទ!មានគ្នា១០០ដែរ ។

វណ្ណៈ ចឹងថា១០០នាក់ចុះព្រោះមាន៣០ជាង?

ភានៈ បាទ!វាភ្លេចបាត់ទៅមានបីផ្នែក មួយមានផ្នែកតភ្លើងតាមធម្មតា មួយទៀតតខ្សែដីកប់ក្នុងដីមួយទៀតអ្នកតម្លើងភ្លើងក្នុងរោងចក្របណ្ដោយ ។

វណ្ណៈ ចឹងខាងតភ្លើងមានបីផ្នែកទៀត?

ភានៈ បាទ ។

វណ្ណៈ ហើយខាងម៉ាស៊ីនផ្សេងទៀត?

ភានៈ ខ្ញុំខាងម៉ាស៊ីនខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែខាងបណ្ដាញគេហៅបណ្ដាញណាស់ ។

វណ្ណៈ បាទ!ខាងបណ្ដាញ?

ភានៈ បាទ ។

វណ្ណៈ ចឹងពូនៅហ្នឹងរយៈពេលបីឆ្នាំពូហូបចុកគ្រប់គ្រាន់ទេ?

ភានៈ ហូបគ្រប់គ្រាន់ប៉ុន្មានខែមុនដំបូងហូបមិនគ្រប់ទេ ហូបតែនំប៉័ងបានរយៈពេលកន្លះខែបានហូបចុក ព្រោះអីនៅក្នុងក្រសួងខ្ញុំហ្នឹង បើនិយាយអ្នកដឹកនាំគេធ្វើមិនឲ្យខាងលើដឹងណាស់ ។

វណ្ណៈ បាទ ។

ភានៈ អាចថាគាត់ធ្វើស្របច្បាប់យ៉ាងណាមិនដឹងទេ ព្រោះអីគាត់មានប្រើសហជីពនៅស្ទឹងមានជ័យ ចិញ្ចឹមជ្រូកចិញ្ចឹមទាចឹងអីហើយមានកន្លែងធ្វើស្រែចំការនៅហ្នឹង មានសហករណ៍ឧបត្ថម្ភសហជីប ។

វណ្ណៈ បាទ ។

ភានៈ ពេលទំនេរអ្នកកម្មករធ្វើទំនេរចុះទៅជួយធ្វើស្រែ ចុះទៅជួយភ្ជួរជួយស្ទូងអីចឹងណាស់ ។

វណ្ណៈ បាទ ។

ភានៈ លើកទំនប់ធ្វើស្រែលើកភ្លឺស្រែអីហ្នឹង ។

វណ្ណៈ ចឹងធ្វើអគ្គីសនីដងទៅលើកទំនប់ធ្វើស្រែអីដង?

ភានៈ បាទ!គេមានបង្កើតសហករណ៍សម្រាប់បំរើឲ្យសហជីបហ្នឹង ។

វណ្ណៈ បាទ ។

ភានៈ នៅត្រង់វត្តសំបួរមាសណាស់ ។

វណ្ណៈ បាទ ។

ភានៈ សហករណ៍ហ្នឹងនៅក្នុងគ្រប់ខ័ណ្ឌអគ្គភាពសាធារណៈការតែមួយដែរ ។

វណ្ណៈ បាទ!ដូចថាពូកាលហ្នឹងគេចែកជាកងជាវរៈដែលឬមួយអត់ទេ?

ភានៈ ខ្ញុំអត់ទេ ខ្ញុំចែកចេញជាបីផ្នែកទេ ដូចថាផ្នែក“ក”ខាងចាប់ចរន្តគចរន្តមួយទៀតភ្លេចបាត់ហើយមានបី ។

វណ្ណៈ ចឹងប្រធានដែលគ្រប់គ្រងពូមានឈ្មោះអីដែលពូ?

ភានៈ	អេ ភ្លេចបាត់ហើយ មួយស្អី សាវុធទេមុនដំបូងប្រធានហើយអនុប្រធានហ្នឹងស្អី ម៉ិទេខ្ញុំអត់ចាំដែរ ដល់ឆ្នាំ៧៦-៧៧ដែលគេថាចាប់ចេះចុះទៅបានពីរនាក់ហ្នឹងគេចាប់យកបាត់ទៅមួយមកទៀត ។

វណ្ណៈ	ចឹងម៉ិនិងវុធត្រូវគេចាប់ខ្លួន?

ភានៈ	ម៉ិហ្នឹងចាប់មុន៧៩នេះហើយ ។

វណ្ណៈ	បាទ ។

ភានៈ	ចាប់ហើយបានប៉ុន្មានខែឃួនចូលហ្នឹងបណ្តោយ ។

វណ្ណៈ	ចឹងអត់មានទាន់ផ្លាស់ប្រធានថ្មីមកទេ?

ភានៈ	មានផ្លាស់មកមួយទៀត ភ្លេចបាត់ហើយអាក្រោយហ្នឹងមិនដឹងជាឈ្មោះអី អាហ្នឹងមកពីខាងផ្នែកនិរតី ។

វណ្ណៈ	បាទ ។

ភានៈ	ឈ្មោះអីខ្ញុំភ្លេចបាត់ហើយ យូរពេកហើយមិនបានចាប់អារម្មណ៍ ។

វណ្ណៈ	បាទ! ចឹងពូកាលហ្នឹងពូអត់មានឋានៈអីទេ?

ភានៈ	ខ្ញុំអត់មានអីទេ ខ្ញុំគេឲ្យនៅចាំឃ្លាំង ខ្ញុំចេញពីចាំឃ្លាំងមកខ្ញុំទៅធ្វើកម្មករតាមគេជាសមាជិកគេណាស់ ។

វណ្ណៈ	បាទ ។

ភានៈ	មានតែកាតាបមួយហ្នឹងមានទុលលីសមានដែកកាប់មួយចឹងតភ្លើងតអីហ្នឹងទេ ។

វណ្ណៈ	បាទ ។

ភានៈ	ហើយមានឡានមួយដឹកក្នុងក្រុមហ្នឹង ។

វណ្ណៈ	ចឹងពូមានសង្កេតឃើញនៅក្នុងភ្នំពេញហ្នឹងមានសភាពស្ងប់ស្ងាត់ឬមួយអូរអរយ៉ាងម៉េចដែរ?

ភានៈ	នៅក្នុងភ្នំពេញស្ងាត់ឈឹងបណ្តោយណាស់មានស្អី ចេញពីផ្សារតូចហ្នឹង កាលហ្នឹងមានទូរស័ព្ទវៃណាស់ ។

វណ្ណៈ	បាទ ។

ភានៈ	ដូចថាគេគេមកពីណាខទាហរណ៍ថាពីក្បាលថ្នល់ចូលចឹងមកយើងយកឡានទៅធ្វើឲ្យគេចឹងទៅទៅទូតអីចឹងទៅ ។

វណ្ណៈ	កាលហ្នឹងមានទូតអីខ្លះដែរ?

ភានៈ អត់ទេ អត់ចាំ មើលមានទូតយួន ទូតគុយបា មានទូតអីខ្លះទេខ្ញុំភ្លេចហើយ ទូចចិនក៏មានកូរ៉េ ។

វណ្ណៈ កាលហ្នឹងកូរ៉េជើងកូរ៉េត្បូង?

ភានៈ ទេ កាលហ្នឹងមិនដឹងជាកូរ៉េជើងត្បូងដែរ ។

វណ្ណៈ ចឹងគុយបាមាន?

ភានៈ គុយបាមាន ។

វណ្ណៈ ប៉ុន្តែទូតយួនហ្នឹងមិនមែននៅរហូតទេ នៅឆ្នាំណាដែលគេដេញទៅវិញនោះពូមានបានដឹងទេ?

ភានៈ ខ្ញុំមិនបានដឹងផង ព្រោះអីកាលពីឆ្នាំ៧៧ខ្ញុំទៅនៅកំពង់សោមហើយណាស់ ចឹងខ្ញុំមិនដឹងថាទូតយួនគេដេញចេញឬមួយយ៉ាងម៉េចខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ កាលហ្នឹងយើង៧៧-៧៨ហ្នឹងចាប់ផ្តើមវៃជាមួយយួនហើយ ដូច្នេះមិនអាចមានទូតយួនទៀតបានទេ?

ភានៈ បាទ ។

វណ្ណៈ មានតែគុយបា មានកូរ៉េ ចិន?

ភានៈ កាលពី៧៦-៧៧ដើម៧៧នៅមាន ព្រោះអីខ្ញុំនៅកាលមិនទាន់ចេញពីភ្នំពេញទៅនៅកំពង់សោមឃើញមាននៅហ្នឹង ។

វណ្ណៈ បាទ ។

ភានៈ កាលហ្នឹងខ្ញុំចូលទៅធ្វើភ្លើងអីនៅកន្លែងហ្នឹងដែលតើ ។

វណ្ណៈ កន្លែងទូតយួនហ្នឹង?

ភានៈ កន្លែងយួនហ្នឹង បើថានៅមានជនចំរើនបានចូលបាន ទៅតភ្លើងហ្នឹងជនចំរើនបានទៅតបានកាលហ្នឹងចូលមិនបានទេ គេលាក់ការណ៍គេដែរ ។

វណ្ណៈ បាទ ។

ភានៈ ក្រៅពីហ្នឹងចូលបានទាំងអស់ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដែលឃើញថ្នាក់ដឹកនាំធំៗដូចជា ប៉ុល ពត នួន ជា ខៀវ សំផនហៅទៅប្រជុំស្តាតឬមួយយ៉ាងម៉េចដែលកាលហ្នឹង?

ភានៈ ជំនាន់ហ្នឹង កាលហ្នឹងខ្ញុំអត់មានដែលបានជួបគាៗហ្នឹងផង ជួបតែប្រធានក្រសួងហ្នឹងបណ្តោយក្រសួងសាធារណការហ្នឹង ។

វណ្ណៈ ពីណាគេ?

ភានៈ ទូច ភឿន ។

វណ្ណៈ ទូច ភឿន?

ភានៈ ទូច ភឺន ។

វណ្ណៈ ទូច ភឺនហ្នឹងមាននៅរស់ទេ?

ភានៈ ទេ បាត់តាំងពីហ្នឹងមកមិនដឹងជាទៅណាមកណាទេ ។

វណ្ណៈ ទូច ភឺន?

ភានៈ បាទ!ទីស្នាក់ការគាត់នៅខាងត្បូងវត្តភ្នំជាប់ ។

វណ្ណៈ ចឹងពូនៅរយៈពេលបីឆ្នាំពូមានដែលសុំគេទៅលេងស្រុកកំណើតអីទេ?

ភានៈ អត់ដែលសុំផង ព្រោះចេះកាលគេឆ្នាំ៧៧មានគេមកមុនគេទៅសុំណាស់ឬអគ្គភាពមុនសុំគេអ្នកនៅហ្នឹង គេនេះគេមិនចឹងទៅលេងផ្ទះហើយពួកខ្ញុំដែលទើបមកមិនទាន់ចង់ទៅលេងផ្ទះទេ ។

វណ្ណៈ បាទ ។

ភានៈ មានកន្លែងណាមួយនោះទៅដល់ឃើញសហករណ៍ឃើញមិនស្រួលធ្វើបាបគេបាញ់គេ វ៉ៃគេនៅហ្នឹង ទៅឃើញក្នុងភូមិស្រុកកំណើតខ្លួនឯងវាអត់បាយអត់ទឹកយ៉ាងម៉េច អាហ្នឹងខ្ញុំពុគាមគេ ។

វណ្ណៈ បាទ ។

ភានៈ ដល់ចឹងអ្នកដែលមកក្រោយដូចខ្ញុំចឹង មិនហ៊ានសុំគេទៅ ព្រោះអីគេថាមានកន្លែងមានគេនៅហ្នឹងទទួលខុសត្រូវមានពេទ្យមានអីហើយយើងមិនបាច់ទៅទេ យើងធ្វើតែការងារយើងទៅ ។

វណ្ណៈ បាទ ។

ភានៈ ហើយអ្នកដែលទើបមកក្រោយៗចឹងអត់មាននឹកនាឃើញសុំទៅទេ ។

វណ្ណៈ ហើយអ្នកដែលសុំទៅបានទៅហេងស៊យមានបញ្ហាទៀត?

ភានៈ មកវិញមានបញ្ហាព្រោះអីកាលយើងទៅដូចថាទៅធ្វើសកម្មភាពនៅហ្នឹងចុងណាស់ ដល់ពេលមកវិញដឹងជាយ៉ាងម៉េចបាត់ខ្លួនឬមួយយ៉ាងម៉េចយ៉ាងម៉ា ដល់ចឹងអាអ្នកក្រោយល្អហើយអត់ហ៊ានទៅទៀតទេ ។

វណ្ណៈ ចុះដល់ពេលទៅឃើញនៅស្រុកភូមិឪពុកម្តាយបងប្អូនហូបអត់ឆ្អែតចឹងមានចិត្តខឹងឬមួយយ៉ាងម៉េច?

ភានៈ បាទ ។

វណ្ណៈ ប៉ុន្តែអ្នកនៅភ្នំពេញជាកម្មករជាយោធាអី មានរបបហូបចុកគ្រប់គ្រាន់មែន?

ភានៈ បាទ ។

វណ្ណៈ កន្លែងណាដូចជាកន្លែងណាដែរ ខ្ញុំសួរទៅ?

ភានៈ បាទ ។

វណ្ណៈ តែអ្នកស្រុកអ្នកភូមិអីត្រូវគេយកទៅសម្លាប់មួយចំនួនហើយអត់មានអាហារ?

ភានៈ បាទ ។

វណ្ណៈ តែទោះបីជាសម័យហ្នឹងពូមិនបានដឹងដូចជាពូមិនបានឃើញផ្ទាល់ភ្នែកមែន?

ភានៈ បាទ ។

វណ្ណៈ តែក្រោយមកពូមានជឿថាមានសម្លាប់មនុស្សចឹងមែនដែលអត់ ពូជឿដែលឬមួយមិនជឿទេកាលហ្នឹង?

ភានៈ ខ្ញុំជឿខ្លះមិនជឿខ្លះ មិនជឿត្រង់ថា វាចេះព្រោះអីអ្នកដែលសម្លាប់គឺវាមានខ្លះៗខ្ញុំជឿ ។

វណ្ណៈ បាទ ។

ភានៈ វាសម្លាប់វាមានផ្ទាញ់ផ្ទារគ្នា ។

វណ្ណៈ បាទ ។

ភានៈ អាហ្នឹងទី១ខ្ញុំដឹងថាចឹងទេ ត្រង់ថាឲ្យឃើញគេចាប់យកទៅតែម្ដង ព្រោះអីខ្ញុំនៅនេះភាគច្រើនអត់ដឹងតែម្ដង ។

វណ្ណៈ បាទ ។

ភានៈ បើនិយាយពីសហករណ៍នេះ អត់អាហារចេះចុះខ្ញុំគ្រាន់តែពុៗទេ ខ្ញុំមិនបានដឹងទេ ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងពូមិនបានដឹងថាខាងក្រោយវេទនាអីទេ?

ភានៈ បាទ!អត់ដឹងទេ ។

វណ្ណៈ ចឹងកាលហ្នឹងបងប្អូនពូក៏មិនអីដែលគ្រាន់តែមានបាត់ខ្លួនបាត់អី ប៉ុន្តែអត់មានស្លាប់ដោយសារអត់អាហារទេ?

ភានៈ អត់ដឹងបណ្ដោយកន្លែងហ្នឹងមិនបានដឹងស្លាត់ឈឹង ខ្លួនខ្ញុំនៅសម្ងំសុខតែខ្លួនឯងមកព្រោះអីចូលភ្នំពេញហ្នឹងមកហើយចេញទៅកំពង់សោម ចេញពីកំពង់សោមមកហ្នឹងតែម្ដង ។

វណ្ណៈ ចឹងបងប្អូនពូមានស្លាប់ពីរនាក់ចឹង?

ភានៈ ស្លាប់ពីរនាក់ ។

វណ្ណៈ ចឹងម្នាក់ទៀតស្លាប់នៅពេលណា?

ភានៈ ម្នាក់ទៀតស្លាប់តាំងពី៧១ គាត់ស្លាប់តាមនេះទេ ស្លាប់តាមជំងឺគាត់ទេ ។

វណ្ណៈ  បាទ ។

ភាន់ៈ  ស្លាប់កាលកូនខ្ញុំគាត់ខ្យល់គដួល ។

វណ្ណៈ  បាទ ។

ភាន់ៈ  ខ្ញុំទើបពុកាលទៅស្រុកទេ បងប្អូនខ្ញុំប្រាប់ ។

វណ្ណៈ  បាទ ។

ភាន់ៈ  បើថាបងខ្ញុំឈ្មោះញានេះ ដឹងថាគេសម្លាប់ហើយព្រោះអីគាត់នៅធ្វើការនៅហ្នឹងណាស់ ។

វណ្ណៈ  បាទ! ចឹងនៅកន្លែងកងពូហ្នឹងមានផ្លាស់យុវជនប្តុមួយមានអ្នកបាត់ខ្លួនអីទេ ក្រុមអគ្គីសនីអីហ្នឹងមានចាប់ខ្លួនមេៗមានបាត់ខ្លួនមនុស្សមួយចំនួននៅក្នុងអង្គភាពហ្នឹងទេ?

ភាន់ៈ  មាន ។

វណ្ណៈ  តែពូមិនដឹងជាគេយកទៅណា?

ភាន់ៈ  មិនដឹងជាយកទៅណាទេ ដឹងថាយកទៅរៀនតែមិនឃើញមកវិញ យកទៅរៀនសូត្រចឹងម្តងពីរដងអ្នកក្រោយចេះតែខ្លាចហើយប្រុសប្រយ័ត្នខ្លាចមានបញ្ហាដល់ខ្លួន ខ្លាចគេយកទៅណាស់ហើយម្នាក់ៗពុថាអង្គការហៅទៅរៀនចេះចុះភ័យហើយ ។

វណ្ណៈ  បាទ ។

ភាន់ៈ  ព្រោះអីឲ្យតែទៅរៀនមិនដែលឃើញមកវិញ ខ្ញុំមានផលវិបាកមួយដែរ ប៉ុន្តែខ្ញុំដូចថាទឹកដោះម្តាយថ្ងៃយ៉ាងម៉េច ព្រោះខ្ញុំធ្លាប់បានប្រឆាំងគេម្តងដែរ ម៉ាម៉ាត់ពីរម៉ាត់ចឹងគេដកសេចក្តីទុកចិត្តចេញពីអគ្គីសនីហ្នឹង តែនៅក្នុងក្រសួងខ្លួនឯងដដែលតែទៅនៅក្នុងសហករណ៍ស្ទឹងមានជ័យហ្នឹងណាស់ ។

វណ្ណៈ  បាទ ។

ភាន់ៈ  រាល់ដងយើងមកគភ្លើងខ្សែភ្លើងនៅក្នុងក្រុងមិនចឹង ដល់ពេលមានបញ្ហាអីខ្ញុំតមាត់តកគេទៅគេដកខ្ញុំទៅនៅសហករណ៍ទៅភ្នួរស្រែបានប្រហែលជាកន្លះខែ ។

វណ្ណៈ  បាទ ។

ភាន់ៈ  អនុប្រធានក្រសួងហ្នឹងគាត់នៅចាក់អង្រែហើយកម្មករនៅក្នុងភ្នំពេញហ្នឹងគេត្រូវការភ្លើងច្រើនណាស់ ព្រោះអីចង់និយាយភ្លៀវប្តុមួយតាមផ្ទះអីអង្គភាពអីត្រូវការភ្លើងដល់ហៅទៅវាអត់មានមនុស្សទៅធ្វើឲ្យគេ ។

វណ្ណៈ  បាទ ។

ភាន: បេះតែបាត់ទៅៗដល់ចឹងអនុប្រធានក្រសួងហ្នឹង គាត់ចេញទៅសហករណ៍ព្រោះសហករណ៍ក៏គាត់ជាអ្នកបង្កើតដែរ ។

វណ្ណៈ បាទ ។

ភាន: ដល់ចឹងគាត់តាមដានទៅសហករណ៍ឃើញកំលាំងនៅហ្នឹងបណ្តោយ ។

វណ្ណៈ បាទ ។

ភាន: ទៅសួរថាអាអូនឯងមកពីជំនាន់ណាៗគាត់សួរចឹងតែម្តង ចឹងហើយយើងប្រាប់គាត់ថាខ្ញុំមកប្រហែលជាកន្លះខែមូលហេតុអីចឹងទៅ ខ្ញុំថាអត់ដឹងរឿង ដល់ចឹងគាត់ស្រាវជ្រាវមានគេឲ្យការណ៍មកគាត់ដែរ ឥឡូវអាអូនឯងទើបមកបាន៧ថ្ងៃទេ ចឹងប្អូនឯងស្អែកមិនបាច់ចុះសហករណ៍ទេ មិនបាច់ទៅធ្វើការទេ ចាំបងមកយក ។

វណ្ណៈ ចឹងកាលហ្នឹងពូថាគមាត់ជាមួយគេថាយ៉ាងម៉េច?

ភាន: គមាត់យើងចង់និយាយថា យើងធ្វើការហើយគេមិនប្រជុំដកពិសោធន៍ យើងធ្វើការមានបញ្ហាខ្វះខាតឲ្យយើងកែប្រែខ្លួនណាស់ ថ្ងៃហ្នឹងខ្ញុំរាងជិនះដែលថាខ្ញុំមិនដឹងជាកែប្រែយ៉ាងម៉េចមិនដឹងជាប្តេជ្ញាថាម៉េច បើប្តេជ្ញាទៅខ្លាចលោខ្ញុំធ្វើមិនបានទៀត ។

វណ្ណៈ បាទ ។

ភាន: ឧទាហរណ៍ថាឥឡូវខ្ញុំឈប់ហើយ ឧទាហរណ៍ថាឈប់លួចគេចង់និយាយចឹង ។

វណ្ណៈ បាទ ។

ភាន: ចង់និយាយចឹងណាស់ ឲ្យខ្ញុំឈប់វិញខ្ញុំខ្លាចធ្វើវាមិនបានក្រែលោមានលួចគេទៀត ។

វណ្ណៈ បាទ ។

ភាន: ខ្ញុំឧទាហរណ៍ចឹងណាស់ ។

វណ្ណៈ បាទ ។

ភាន: ព្រោះអីខ្ញុំប្រឆាំងគេចឹង ឲ្យខ្ញុំប្តេជ្ញាចិត្តយ៉ាងម៉េច លោខ្ញុំធ្វើវាមិនបាន ។

វណ្ណៈ បាទ ។ណ

ភាន: និយាយតែប៉ុណ្ណឹងទេ គេដកសច្ចក្តីទុកចិត្តស្អែកឡើង ។

វណ្ណៈ អ្នកដែលពូតវ៉ាជាមួយឈ្មោះអីប្រធានហ្នឹង?

ភាន: អាហ្នឹងអ្នកមកក្រោយ អាវុធទៅបាត់ហើយអ្នកមកក្រោយណាស់ ភ្លេចឈ្មោះហើយឈ្មោះស្អីទេ ភ្លេចបាត់ហើយដល់ខ្ញុំតវ៉ាចុះឡើងៗចឹងឯងហ្នឹងមានតែស្មៀនអាវុធ ថាខ្ញុំស្មៀនអាវុធអាវុធដែលគេចាប់ហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ភានៈ ចុះកាលហ្នឹងគេចាប់ចេញទៅសុទ្ធតែខ្មាំងហើយកាលហ្នឹង ឲ្យតែគេចាប់ដឹងថាហោអាហើយ ។

វណ្ណៈ បាទ ។

ភានៈ ចឹងគេថាឯងមានតែស្មៀនអាវុធចឹងទៅ បើប្តេជ្ញាចិត្តធ្វើប៉ុណ្ណឹងមិនបានមានតែទៅកន្លែងដែលអាអូនឯងទៅធ្វើ ។

វណ្ណៈ បាទ ។

ភានៈ ចឹងបានជាឲ្យខ្ញុំទៅសហករណ៍ហ្នឹង នៅគ្នាតែខ្ញុំប៉ុន្មាននាក់ហ្នឹងដល់ខ្ញុំតមាត់តកចឹងទៅនៅសហករណ៍បាន១០ថ្ងៃបានខ្ញុំចេញពីហ្នឹងទៅទៀតបានអនុប្រធានសហករណ៍គាត់ទៅយកហ្នឹង មិនមែនខ្ញុំម្នាក់ឯងទេ មានគ្នា៥នាក់ ។

វណ្ណៈ បាទ ។

ភានៈ យកខ្ញុំចេញមកយកទៅដាក់កន្លែងគាត់នៅអគ្គិសនីកន្លែងចាក់អង្រែហ្នឹង ។

វណ្ណៈ បាទ ។

ភានៈ គាត់រៀបចំខ្លួនអីអស់កាត់សក់អីបើកខោបើអាវបើកស្បែកជើងមួកអីចឹងមកចេញមកកកំពង់សោមបណ្តោយ ។

វណ្ណៈ ចឹងអគ្គិសនីហ្នឹងតភ្លើងនៅក្នុងភ្នំពេញហ្នឹងតែម្តង គ្រប់កន្លែង?

ភានៈ គ្រប់កន្លែងដែរ ឲ្យតែគេថាដាច់ភ្លើងកន្លែងណាទៅកន្លែងហ្នឹងហើយ ។

វណ្ណៈ ចឹងមានកន្លែងស្ថានទូតដែរ?

ភានៈ បាទ ។

វណ្ណៈ ចឹងមានស្ថានទូតនិងរោងចក្រ?

ភានៈ បាទ!ស្ថានទូតរោងចក្រតាមអគ្គភាពរថក្រោះគ្រប់កន្លែងឲ្យតែមានឲ្យតែគេត្រូវការភ្លើង ។

វណ្ណៈ ចឹងពេលពូដល់ក្នុងភ្នំពេញហ្នឹងដូចថាអ្នកដែលធ្លាប់ធ្វើទាហាន ទៅធ្វើជាកម្មករអស់ហើយលែងមានកាំភ្លើងប្រូងប្រាងអីលែងមានហើយឬនៅមានទៀត?

ភានៈ ដូចជាអត់មានទេ មានតែអគ្គភាពទ័ពគេដូចថាមួយបន្ទាយចឹងណាស់ មានតែពួកហ្នឹងទេ ក្រៅពីហ្នឹងតាមរោងចក្រអីអត់មានទេ ឬថាមេមានលាក់កាំភ្លើងអីយ៉ាងម៉េចមិនដឹងទេ ។

វណ្ណៈ បាទ ។

ភានៈ តែអត់មានកាំភ្លើងវែងអត់មានទេ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដែលបានតភ្លើងនៅក្នុងវាំងអីទេ?

ភាន៖ ក្នុងវាំងខ្ញុំមិនដែលចូលបានតទេ ។

វណ្ណៈ ចឹងពូមានបានដឹងថាជំនាន់បីឆ្នាំហ្នឹងសម្តេចសីហនុត្រូវបានឃុំខ្លួននៅក្នុងវាំងទេ?

ភាន៖ ខ្ញុំអត់ដឹង សម្តេចនៅហ្នឹងខ្ញុំមិនបានដឹងទេ ព្រោះអីក្នុងវាំងខ្ញុំមិនដែលបានចូល ។

វណ្ណៈ កាលហ្នឹងសម្តេចសីហនុគាត់នៅក្នុងវាំងរហូតដែរ នៅពេលវៀតណាមជិតចូលមកដល់នៅឆ្នាំ ១៩៧៩ហ្នឹង មុនវៀតណាមចូលមកដល់ប្រហែលជា៥ ទៅ៦ថ្ងៃហ្នឹងបានគាត់នៅចិន មុនហ្នឹងគាត់នៅហ្នឹងរហូតទេ?

ភាន៖ គ្រាន់តែដឹងថាសម្តេចនៅហ្នឹង តែមិនដឹងពិតមែនឬអត់ខ្ញុំមិនដែលបានចូល ។

វណ្ណៈ ចឹងកាលពូនៅភ្នំពេញបីឆ្នាំហ្នឹងគេមិនដែលឲ្យជួបសម្តេចដែរ?

ភាន៖ បាទ!អត់ទេ ។

វណ្ណៈ ចឹងកន្លែងពូផ្នែកអគ្គិសនីហ្នឹងមានបានទៅទទួលភ្ញៀវចិនអីទេ តាមពោធិចិនតុងអីដែលអត់ទេ?

ភាន៖ អត់ផង ។

វណ្ណៈ អត់មានទេ?

ភាន៖ បាទ!ទៅជួបពេលដែលកន្លែងហ្នឹងដាច់ភ្លើងខ្ញុំទៅជួបមានដែល ។

វណ្ណៈ ចឹង?

ភាន៖ បាទ ។

វណ្ណៈ ចឹងពួកចិនអីហ្នឹងគេមានរាក់ទាក់យើងដែលអត់ទេ?

ភាន៖ ចិនរាក់ទាក់ធម្មតាមានអីចិន មានចិន កូរ៉េ គុយបាអីហ្នឹងនិយាយរួមអត់មានថា មិនរាក់ទាក់ទេ គ្រាន់តែនិយាយស្តាប់គ្នាមិនបាន ។

វណ្ណៈ ចឹងនៅពេលយើងទៅតភ្លើងមានអ្នកបកប្រែឲ្យយើង?

ភាន៖ បាទមាន ។

វណ្ណៈ ឲ្យយើងធ្វើអីៗៗចឹង?

ភាន៖ បាទ!ហ្នឹងហើយ ។

វណ្ណៈ ចឹងនៅពេលវៀតណាមវ៉ៃចូលកាលឆ្នាំ៧៩ហ្នឹង ហេតុអីបានជាពូមិនទៅស្រុក?

ភាន៖ ខ្ញុំដូរឆ្ងាយខ្ញុំនៅកំពង់សោមនោះ ខ្ញុំ៧៧-៧៨ខ្ញុំទៅនៅកំពង់សោម កន្លែងខ្ញុំនិយាយថាគេចាត់ខ្ញុំឲ្យទៅសហករណ៍ដល់គេចូលមកយកទៅធ្វើការយកខ្ញុំទៅធ្វើការនៅកំពង់សោមនោះ ។

វណ្ណៈ ចឹងទៅកំពង់សោម?

ភានៈ បាទ!កំពង់សោមហ្នឹងទៅធ្វើនេះវ៉ារីអគ្គីសនីកើតថ្មីនៅកំពង់សោមនៅស្ទឹងប្រាលហ្នឹងណាស់ ខ្ញុំ កំពង់តែស្តាយដែលកន្លែងហ្នឹងមួយចិនវ៉ាមកស្រាវជ្រាវធ្វើវ៉ារីអគ្គីសនីហ្នឹងវ៉ាបាត់ស្ងាត់ឈឹងទៅណាស់ ឯកសារឡើងពីរពាងនោះកប់នៅហ្នឹង ។

វណ្ណៈ អ្វី?

ភានៈ ដល់ហើយវ៉ារីអគ្គីសនីកន្លែងហ្នឹងយកមក ។

វណ្ណៈ វ៉ារីអគ្គីសនីស្ទឹងអីគេកាលហ្នឹង?

ភានៈ ស្ទឹងគេហៅថាវ៉ារីអគ្គីសនីស្ទឹងអីជង កន្លែងមានទំនប់រលួសហ្នឹងវ៉ារលួសហ្នឹងគេធ្វើនៅពីលើវ៉ារលួសហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ភានៈ ហើយគេយកភ្លើងហ្នឹងមកជំនួយដល់កន្លែងស្ទឹងប្រាល ។

វណ្ណៈ ចឹងកាលដែលពូទៅធ្វើហ្នឹងធ្វើបានអីខ្លះហើយ?

ភានៈ ខ្ញុំបានវ៉ាស់ស្ទង់ទឹកន្លែងទាំងអស់ហើយហ្នឹងដើងទំនប់ហ្នឹងខ្ទង់អស់ហើយហ្នឹង ។

វណ្ណៈ កាលហ្នឹងបច្ចេកទេសខាងណាចិនឬក៏ខាងណា?

ភានៈ ចិន ។

វណ្ណៈ ចឹងអ្នកបច្ចេកទេសចិន?

ភានៈ បាទ!ទំបន់ហ្នឹងខ្ទង់អស់ហើយបាតទំបន់ហ្នឹងខ្ទង់បានថ្មបានអីយកមកដឹងថា ។

វណ្ណៈ ចឹងឆ្នាំ៧៨ហ្នឹងពូទៅកំពង់សោមធ្វើវ៉ារីអគ្គីសនី?

ភានៈ បាទ!ទៅវ៉ាស់ស្ទង់ ។

វណ្ណៈ ចឹងពូចេញពីអគ្គសនីហើយ?

ភានៈ ចេញពីអគ្គីសនី ប៉ុន្តែនៅក្នុងអង្គភាពសាធារណៈការដដែលហ្នឹង ។

វណ្ណៈ បាទ ។

ភានៈ គ្រាន់តែដូរកន្លែង ។

វណ្ណៈ បាទ!ចឹងមកកំពង់សោមដល់ឆ្នាំ៧៩?

ភានៈ បាទ!រហូតដល់យួនចូលបណ្តោយ ។

វណ្ណៈ បាទ!យួនចូលពូរត់ទៅខាងណាវិញ?

ភាន៖ ខ្ញុំរត់មកតាមថ្នល់ផ្លូវរទេះភ្លើងធ្វើថ្មីហ្នឹង រត់មកកើតចឹងមក មកធ្លាក់ណាស្រុកស្រែអំបិលហ្នឹង រហូតមកដល់ណា និយាយតាមតែសៀវភ្នំតាមព្រំដែនហ្នឹងរហូតមកដល់ហ្នឹងបណ្តោយដល់សំឡូតនៅសំឡូតចេញពីសំឡូតមក៩៣-៩៥មកនេះហើយ ។

វណ្ណៈ ចឹងពូកាលហ្នឹងគិតយ៉ាងម៉េចបានជាមិនមករកផ្ទះខ្លាចយួនឬមួយក៏យ៉ាងម៉េច?

ភាន៖ កាលហ្នឹងខ្លាចយួនបណ្តោយ ម្យ៉ាងនិយាយរួមថាខ្លាចបណ្តោយណាមួយផ្លូវឆ្ងាយមិនហ៊ានឆ្លងកាត់ទៅស្រុកពីកំពង់សោមទៅស្រុកកោះសូទិនមិនធម្មតាទេ កំពង់ចាម ។

វណ្ណៈ បាទ ។

ភាន៖ ត្រូវកាត់ខេត្តណាអីខេត្តណាយើងអត់ស្គាល់ កាលហ្នឹងនៅតូចដែលអាយុ១៨ទៅ១៩ហ្នឹង ។

វណ្ណៈ ចឹងកាលដែលពូរត់ទៅកាលឆ្នាំ៧៩ហ្នឹង រត់ទៅទាំងកងពូតែម្តង?

ភាន៖ រត់ទៅទាំងកង ។

វណ្ណៈ ចឹងមានមនុស្សរាប់រយនាក់រាប់ពាន់នាក់?

ភាន៖ បាទ!រាប់ពាន់នាក់តាំងពីកម្មករកំពង់សោម កម្មករនៅកំពង់ផែអីរត់មកជាមួយគ្នារត់មកហ្នឹងទាំងអស់ចេញមកតាមផ្លូវថ្នល់រទេះភ្លើងហើយហ្នឹងទើបធ្វើថ្មីហ្នឹង តែគ្រាន់តែមិនទាន់ត្រួសត្រាយនៅឡើយទេ ។

វណ្ណៈ ចឹងពូគិតមើលរត់នៅឆ្នាំ៧៩ហ្នឹង ទំរាំតែបានទៅដល់ជំរំហ្នឹងទំរាំទៅដល់ជាយដែនហ្នឹង តើមានមនុស្សស្លាប់តាមផ្លូវទេ?

ភាន៖ មានស្លាប់ច្រើន ។

វណ្ណៈ ស្លាប់ដោយសារអីគេ?

ភាន៖ ពីនោះមកស្លាប់ដោយបាត់ខ្លួនស្លាប់ដោយគេស្ទាក់វ៉ៃហ្នឹងបាត់ខ្លួនអាហ្នឹងដឹងថាស្លាប់ហើយណាស់ ។

វណ្ណៈ បាទ ។

ភាន៖ ហើយមួយទៀតដោយលិចទឹកលង់ទឹកស្លាប់ ។

វណ្ណៈ យ៉ាងម៉េចបានជាលង់ទឹក?

ភាន៖ ឆ្លងទឹកវាហែលមិនរួច ។

វណ្ណៈ ហែលទឹកស្ទឹងអីហ្នឹង?

ភាន៖ បាទ!ទឹកធំ ។

វណ្ណៈ ចឹងឃើញទឹកចឹងយើងថយក្រោយមកវិញបានទេ?

ភានៈ អត់មានថយទេ គេថាត្រូវតែឆ្លងចឹងយើងមិនចាប់ផ្ដើមឆ្លងអ្នកខ្លះដុតដៃដុតជើងទៅក្រោយមានពីណាជួយ ។

វណ្ណៈ បាទ ។

ភានៈ ហើយដុតពីហ្នឹងមកទៀតឡើងភ្នំវែតប់គ្នាត្រូវគ្រាប់ផ្លោងខ្លះ របួសរត់ចោលគ្នា ។

វណ្ណៈ ចឹងពូរត់ដល់សំឡូតនៅឆ្នាំ៧៩ហ្នឹងដែរ?

ភានៈ បាទ!៧៩ហ្នឹងដែលដល់សំឡូត ។

វណ្ណៈ ប្រហែលជាប៉ុន្មានខែដែលដល់សំឡូត?

ភានៈ ទេ កាលហ្នឹងមកដល់សំឡូតហ្នឹងខែភ្លៀងខ្លាំងហើយហ្នឹងនៅសំឡូតយើងរត់កាលហ្នឹងមិនដឹងជាខែប៉ុន្មានទេ ។

វណ្ណៈ ប្រហែលជាបីខែដែលបានសំឡូត?

ភានៈ បាទ ។

វណ្ណៈ ចឹងនៅពេលដែលដល់សំឡូតហ្នឹងគេបង្កើតកងកំលាំងខ្មែរក្រហមរបៀបយ៉ាងម៉េចដែរ?

ភានៈ កាលហ្នឹងមិនទាន់បង្កើតទេ យើងនៅជាកងជាអីចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ភានៈ ជាកងយើងទៅនៅព្រំដែនហ្នឹងនៅតាមកងតាមក្រុមហ្នឹងដែរ យើងឡើងទៅយកអង្ករជំនួយពីហ្នឹងមក ។

វណ្ណៈ បាទ ។

ភានៈ ដល់ពេលយើងនៅហ្នឹងបែហែលជាបានមួយឆ្នាំ អឺ!កន្លះឆ្នាំ ។

វណ្ណៈ បាទ ។

ភានៈ រាងរាំងបន្តិច ។

វណ្ណៈ បាទ ។

ភានៈ រាងបន្តិចគេយកយើងមកសមរភូមិមុខតែម្ដង ចូលអង្គភាពវ៉ៃទប់ទល់នៅមុខបណ្ដោយ ។

វណ្ណៈ បាទ ។

ភានៈ បើយើងនិយាយឥឡូវថាចូលបន្ទាយអីចឹងណាស់ ។

វណ្ណៈ បាទ!កាលហ្នឹងបង្កើតអង្គភាពឡើងវិញចឹងខាងកំលាំងអត់មានប្រាក់ខែទេពូ?

ភានៈ បាទ!អត់មានប្រាក់ខែទេ ។

វណ្ណៈ ចឹងយើងតស៊ូដោយចិត្តស្មោះតែម្ដង?

ភាន៖ តស៊ូដោយស្មោះគ្មានអង្ករអីមានប៉ុន្មានហូបប៉ុណ្ណឹងឯង ។

វណ្ណៈ ចឹងហូបអាហារគ្រប់គ្រាន់?

ភាន៖ ហូបអាហារថាគ្រប់គ្រាន់ក៏ថាបាន ព្រោះអីយើងហូបតែត្រឹមអត់មាននេះផង ។

វណ្ណៈ បាទ ។

ភាន៖ ត្រឹមកំប៉ុង ។

វណ្ណៈ ហើយកាលនៅសំឡូតហ្នឹងពីណាជាប្រធានកងពល?

ភាន៖ ប្រធានកងពលធំមានម៉ា ម៉េត ។

វណ្ណៈ ម៉ា ម៉េតវិញ?

ភាន៖ តា ម៉េត គេហៅតា ម៉េត០៥ឥឡូវមិនដឹងជានៅណា ។

វណ្ណៈ ចឹងតា ០៦វិញនោះ?

ភាន៖ អត់ស្គាល់ ។

វណ្ណៈ តា ម៉េត០៥ហ្នឹងក្រោយមកតា ម៉ុកសម្លាប់ហើយឬយ៉ាងម៉េច?

ភាន៖ អត់ទេ តា ម៉េតនៅទាល់ឥឡូវហ្នឹង ។

វណ្ណៈ ចឹងតា ម៉េតនៅទេ?

ភាន៖ បាទ ។

វណ្ណៈ ចឹងតា ០៦ទេបានស្លាប់?

ភាន៖ ០៦មិនដែលឮផង ។

វណ្ណៈ ០៦នៅខាងអន្លង់វែង?

ភាន៖ បាទ!០៦សុន សេនដឹងខ្ញុំមិនដឹងដែរ ដឹងថា០៥តា ម៉េតហ្នឹងហើយ ។

វណ្ណៈ ចឹងបន្ទាប់តា ម៉េតមានពីណាគេទៀត?

ភាន៖ បន្ទាប់តា ម៉េតមិនដឹងថាពីណាពីណីទេ ដឹងថាគាត់កងពលធំមកក្រោមកងពលតូចធម្មតាមាន តា ផលចៅហ្វាយរាល់ថ្ងៃហ្នឹង ហើយតា នឹម ។

វណ្ណៈ តា នឹមមានតួនាទីអីដែរ?

ភាន៖ តា នឹមគាត់កងពលដែរ កងពលទី១ កងពលតាំងពីជំនាន់នៅភ្នំពេញគាត់ខាងជើងអាកាសដូច តា ម៉េតដែលហ្នឹង ។

វណ្ណៈ ចឹងក្រោយ៧៩ហ្នឹងគាត់នៅជាប្រធានកងពលដែរ?

ភាន៖ បាទ ។

វណ្ណៈ	កាលនៅសំឡូត?

ភានៈ	បាទ ។

វណ្ណៈ	ចឹងតា មុតអីនោះ?

ភានៈ	តា មុតគាត់កាន់ប្រកជីនារគាំងពីហ្នឹងទៅរហូត ។

វណ្ណៈ	ចឹងតា មុតក្តាប់រួមទាំងអស់?

ភានៈ	បាទ!ក្តាប់រួមទាំងអស់ដល់ប៉ៃលិន ដល់ប៉ៃលិនលោក អ៊ី ឈានផ្សេងដល់ខាងនេះតា មុត ។

វណ្ណៈ	ក្តាប់ពីខេត្តពោធិសាត់ទៅ?

ភានៈ	អត់ទេ ក្តាប់ពីប្រកកោះកុងនេះពីភ្នំខ្មោចពីនេះទៅពីថ្មដានេះទៅដល់សំឡូត ។

វណ្ណៈ	ចឹងគាត់លើតា ម៉េតអីទៀត?

ភានៈ	បាទ!លើតា ម៉េតទៀត ដល់មកខាងនេះមកខ្ញុំមិនបានដឹងទេ តា មុតនិងគាត់ក្តាប់រួមតាម៉េត ហ្នឹងក៏គាត់ប្រធានកងពលធំដែលណាស់ កងពលធំនៅខាងសំឡូត ។

វណ្ណៈ	ម៉ា ម៉េតនិងស៊ូ ម៉េតហ្នឹងតាមមើល?

ភានៈ	ស៊ូ ម៉េតនិង ម៉ា ម៉េតហ្នឹង ។

វណ្ណៈ	ឥឡូវគាត់នៅដែរ?

ភានៈ	បាទ!នៅទេ ។

វណ្ណៈ	ឥឡូវគាត់ធ្វើធំ?

ភានៈ	បាទ!ពូពីមុនមកអាហ្នឹងយើងនិយាយតាមការពិត ពូពីមុនមកម៉េតនិងកូនម៉ា ម៉ែងតែម្តងបាន ជាម៉ា ម៉េត ស៊ូ ម៉េតអីម៉េចមិនដឹងទេណាស់ ។

វណ្ណៈ	បាទ! ម៉ា ម៉ែងពីណាគេ?

ភានៈ	ម៉ា ម៉ែងពូគេថាម៉ាម៉ែងៗដៃគូរប៉ុល ពតអីដែរជិតនាន់ហ្នឹងរៀនសូត្រជាប៉ុល ពតអីហ្នឹង ។

វណ្ណៈ	បាទ ។

ភានៈ	តាមពិតហ្នឹងម៉ា ម៉ែងហ្នឹងគាត់ប្រធានមេធំដូចប៉ុល ពតចឹងតែគាត់ស្លាប់បាត់មិនដឹងជាស្លាប់ រឿងអីមិនបានដឹងទេ ។

វណ្ណៈ	ចឹងពូនៅសំឡូតហ្នឹងបានយូរទេ?

ភានៈ	សំឡូតហ្នឹងខ្ញុំនៅហ្នឹងរហូតដល់៩៥បានខ្ញុំមកនៅនេះ ។

វណ្ណៈ	មើលនៅតាំងពី៧៩ដល់៩៨នៅសំឡូត?

ភានៈ	បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូខាងសំឡូតខាងខ្មែរក្រហមអីមានថៃមកកាស់ត្បូងគាស់អីមែនឬយ៉ាងម៉េច?

ភានៈ មែន យើងបើកច្រកឲ្យគេចូលមករកស៊ីដៃគូរគ្នារកស៊ី បើនិយាយត្បូងខ្ញុំហើយអ្នកត្បូងអ្នកគ្រប់គ្រងម៉ានេះដែរ ។

វណ្ណៈ ចឹង?

ភានៈ បាទ ។

វណ្ណៈ ចឹងពូមានបានទុកបានច្រើនទេ?

ភានៈ អត់ទេ សល់តែគ្រាប់តូចៗរប៉ាតរប៉ាយអស់ហើយគ្មានសល់ទេ ។

វណ្ណៈ ត្បូងហ្នឹងពូយករបៀបម៉េចថៃយកមួយថ្ងៃៗបានច្រើនទេ?

ភានៈ មួយថ្ងៃចង់កើតគីឡូនោះ ។

វណ្ណៈ ចង់៩០គីឡូ?

ភានៈ អត់ទេ ចង់កើតជាគីឡូ ។

វណ្ណៈ ចឹងមិនមែនកាប់ទាំងដីទៅវែងស្រុកវាទេ?

ភានៈ អត់ទេ វាវែងពីយើងទៅហើយលក់ ឡើងទៅលក់ ។

វណ្ណៈ ជនជាតិថៃវាមកវែងខ្លួនវាតើ?

ភានៈ បាទ! ថៃវាមកវែងខ្លួនវាយើងអ្នកគ្រប់គ្រងវា ។

វណ្ណៈ ចឹងយើងជាអ្នកគ្រប់គ្រងវា?

ភានៈ បាទ! មកបាញ់មកឈិតមកវែងមកអីយើងយើងវាស់ដីគិតជា«រ៉ា»អីទៅណាស់ ។

វណ្ណៈ ចឹងយើងវាស់ដីឲ្យវាចឹងយើងគិតលុយតែម្ដង?

ភានៈ បាទ ។

វណ្ណៈ ចឹងវាជីកបានប៉ុន្មានបានទៅ?

ភានៈ បាទ! តែជីកហ្នឹងត្បូងណឹងក៏យើងដឹងពុទាំងអស់គ្នាដែរ ខុបបេដាក់លេខអីហ្នឹងមានអ្នកជំនាញយើងមើលយកអាហ្នឹងទៅព្រំដែន ។

វណ្ណៈ ចឹងពីណាគេជាអ្នកគ្រប់គ្រងនៅហ្នឹងដែរ ខ្ញុំភ្លេចឈ្មោះគាត់ដែរ គាត់ប្រធានបេអ៊ុមនៅនេះដែរហ្នឹង?

ភានៈ តា ជន ។

វណ្ណៈ បាទ! តាជន ។

ភានៈ តា ជនហ្នឹងគាត់កងពលខាងក្រោយទេ គាត់នៅក្រោមតាម៉េតនិងទេ កងពលដោយខ្លួន ។

វណ្ណៈ គាត់ជាអ្នកទទួលខុសត្រូវត្បូងដែរ?

ភានៈ គាត់ខាងភស្តុភា ។

វណ្ណៈ ហ្អឹងហើយគាត់ខាងភស្តុភា តា ជន?

ភានៈ បាទ! តា ជនហ្អឹងនៅក្រោមតា ទិត្យទេ ។

វណ្ណៈ តា ទិត្យហ្អឹងគាត់ធ្វើអីដែរ?

ភានៈ បើនិយាយទៅគាត់បន្ទាប់ៗពីតា ម៉េតដែរ គាត់បែកចែកគ្នានៅ ។

វណ្ណៈ ចឹងគាត់នៅសំឡូតដែរ?

ភានៈ គាត់នៅសំឡូតដែលគាត់នៅ ។

វណ្ណៈ តា ទិត្យសព្វថ្ងៃគាត់នៅហ្អឹងតើ?

ភានៈ ខ្ញុំមិនដឹងជាគាត់នៅណាខ្ញុំមិនសូវដឹងដែលតា ទិត្យ ។

វណ្ណៈ គាត់មានចម្ការនៅខាងផ្លូវសំឡូតដែរ គាត់មានចម្ការជាំតា ង៉ែន ។

ភានៈ បាទ!បែបនៅផ្ដិជាវអីហ្អឹង?

វណ្ណៈ បាទ!ចឹងតា ទិត្យគាត់បន្ទាប់ពីតាម៉េត?

ភានៈ បាទ ។

វណ្ណៈ តា ទិត្យហ្អឹងគាត់ក៏បងប្អូនតា ម៉ុកដែរ?

ភានៈ ខ្ញុំមិនសូវជាដឹងដែលមិនដឹងជាយ៉ាងម៉េច?

វណ្ណៈ ចឹងកាលនៅហ្អឹងមានវៃគ្នាខ្លាំងទេជាមួយវៀតណាមអីហ្អឹង?

ភានៈ កាលជំនាន់ខ្ញុំនៅមិនទាន់វៃជាខ្លាំងទេ ព្រោះអីខ្ញុំចេះកាលពី៧៩-៨០-៨១ហ្អឹងនៅស្ងើរនៅឡើយណាស់ ។

វណ្ណៈ បាទ ។

ភានៈ ដល់ពេលខ្ញុំ៨២ ខ្ញុំដាច់ជើង ។

វណ្ណៈ បាទ ។

ភានៈ ខ្ញុំដាច់ជើងតាំងពី៨២ ចឹងចាប់ពីដាច់ជើងមក៨៣-៨៤បានខ្លាំងវៃរុញច្រានគ្នាទៅវិញទៅមករហូតដល់ពួកខ្ញុំធ្លាក់ដល់ព្រំដែនថៃនោះនៅដីថៃនោះ ។

វណ្ណៈ ចឹងនៅពេលពូដាច់ជើងពីលែងទៅសមរភូមិមុខហើយ?

ភានៈ បាទ!លែងទៅសមរភូមិមុខហើយខ្ញុំនៅខាងក្រោយទេ ។

វណ្ណៈ ចឹងពូរៀបការនៅឆ្នាំណា?

ភាន៖ ខ្ញុំរៀបការនៅឆ្នាំ៩០នេះហ្នឹង ។

វណ្ណៈ ចឹងរៀបការឆ្នាំ៩០រៀបនៅណា?

ភាន៖ រៀបនៅសំឡូត ។

វណ្ណៈ ចឹងកាលហ្នឹងមានភ្លេងការហើយនៅឬនៅតែសែនទេកាលហ្នឹង?

ភាន៖ ការមានភ្លេងមានអីស្រួលបួលព្រោះអីមានគេស្ម័គ្រចិត្តចូលដំរំទៅខ្ញុំនៅក្នុងអន្តភាពចឹងខ្ញុំទៅយកដំរំមកការនៅហ្នឹងមានអាចារ្យមានអីស្រួលបួលដែរ យើងចាប់ផ្ដើមត្រូវរូវគ្នាចាប់ពីឆ្នាំ

វណ្ណៈ ៩៧-៩៨សមាហរណ៍កម្ម?

ភាន៖ អត់ទេ ត្រូវរូវគ្នាមុនដំបូង៨៧-៨៨ហ្នឹងត្រូវគ្នាមួយសារលែងសូវវ៉ៃគ្នាហើយណាស់ ។

វណ្ណៈ បាទ ។

ភាន៖ បាទ!៨៨-៨៩ហ្នឹងចឹងខាងខ្ញុំក៏ធូធារខាងនេះក៏ធូធារអាចស្ទាត់ហើយកាំភ្លើងកាលហ្នឹង ។

វណ្ណៈ បាទ ។

ភាន៖ ដល់ពេលយើងអ៊ុនតាក់ចូលមិន៩០មិនចឹង ។

វណ្ណៈ បាទ ។

ភាន៖ អ៊ុនតាក់ចូលហ្នឹងក៏ខ្ញុំនៅបើកការដ្ឋានធ្វើត្បូងណាស់ តែមិនមែនខ្ញុំទេបើកគេបើកតែខ្ញុំនៅហ្នឹងណាស់ ចឹងយើងធ្វើត្បូងបានចេញចូលចឹងទៅអត់មានប្រទុះប្រទះគ្នាទេ ចង់និយាយចឹង ។

វណ្ណៈ បាទ ។

ភាន៖ ថាការវ៉ៃតប់ហ្នឹងវាឃ្លាតគ្នាឆ្ងាយហើយ កាលហ្នឹងកងពលសុខសប្បាយលែងភ័យព្រួយរឿងគេមកវ៉ៃមកអីហើយ ។

វណ្ណៈ ចឹងសំឡូតកាលហ្នឹងមានអ៊ុនតាក់ចូលដល់ទេ?

ភាន៖ អត់តាក់អត់មានចូលដល់ទេ ។

វណ្ណៈ ចឹងអត់មានបានបោះឆ្នោតទេ?

ភាន៖ បាទៗ!គ្រាន់តែពួកទេមិនបានបោះ ៩៣មានពួកបោះឆ្នោតខ្ញុំមិនបានបោះទេ អ៊ុនតាក់គេដកវិញក៏ខ្ញុំមិនដឹងដែរ ។

វណ្ណៈ ចឹងកាលហ្នឹងពូជាទូទៅចាញ់សង្គ្រាមឬថាមានជំងឺគ្រុនចាញ់អីយើងទៅព្យាបាលមានថ្នាំព្យាបាលត្រឹមត្រូវដែលកាលហ្នឹង?

ភាន៖ បាទ!មានព្យាបាលត្រឹមត្រូវព្រោះអីកាលហ្នឹងមានកាកក្របាទគេខបត្តម្ភណាស់ គេឡើងមកធ្វើមន្ទីរពេទ្យព្រោះអី ដូចខ្ញុំថាឆ្នាំ៨៩អីហ្នឹងវារៀងធូរធារដល់ចឹងមានគេជំនួយ ។

វណ្ណៈ	បាទ ។

ភានៈ	មានមន្ទីរពេទ្យស្រួលបួលហើយ បើកាលពីមុនពី៧៩-៨០-៨១អីហ្នឹងអត់ទាន់មានទេ ម្ចាស់ការខ្លួនឯងថ្នាំពេទ្យមានប៉ុន្មានប៉ុណ្ណឹង ។

វណ្ណៈ	បាទ ។

ភានៈ	ហើយស្លាប់ច្រើនណាស់លោកគ្រូ ។

វណ្ណៈ	បាទ ។

ភានៈ	ស្លាប់ជិតទាន់៨០ និយាយព្រឹខ្លួនទៅនៅជំរំព្រំដែនហ្នឹង មិនទាន់កើតជំរំកាលខ្ញុំទៅ ទៅជាអន្តភាពយើងនៅលើខ្នងទួលហ្នឹង ពេលទឹកឡើងគេហៅទៅយកស្បៀងយកអង្ករពីក្រោមយកពីថៃមកហ្នឹងណាស់ ។

វណ្ណៈ	បាទ ។

ភានៈ	យកមកចែកចាយគ្នាហូបទៅយកទៅសមរភូមិមុខចឹងទៅមួយថ្ងៃមួយយប់មានតែស្លាប់នៅក្នុងអន្តភាពខ្ញុំណាស់ ដើរបែកគ្នាមាន៥ ទៅ៦ នាក់ឬបីនាក់ ។

វណ្ណៈ	ដោយសារចាញ់ឬដោយសារអី?

ភានៈ	បាទ! ដោយសារចាញ់និងដោយសារអត់ហូបមិនគ្រប់គ្រាន់ចឹងណាស់ កាលមុនដំបូងហូបមិនគ្រប់គ្រាន់ទេ ឬយើងហូបត្រពាំងឬក៏លាយអង្ករបន្តិចបន្តួចទៅដល់បានអង្ករហូបមកយើងហូបមកវាជ្រុលខ្លួនទៅជាកើតជំងឺស្លាប់ ។

វណ្ណៈ	ដល់ឆ្នាំណាបានលែងសូវចាញ់?

ភានៈ	ចាញ់នៅតែចាញ់រហូតហ្នឹង តែដល់លែងស្លាប់ហ្នឹងចូលឆ្នាំ៨០ហ្នឹងលែងសូវមានអ្នកជំងឺស្លាប់តាមព្រៃចឹងហើយ ដល់ក្រោយមកគេបាន"...ស្តាប់បានព្រោះអ្នកជិតខាងនិយាយឮឡា" យើងនៅចាញ់រហូតស្លាប់ជាបន្តបន្ទាប់តែមិនច្រើនដូចកាលពី៧៩ហ្នឹង ។

វណ្ណៈ	បាទ ។

ភានៈ	៧៩ហ្នឹងស្លាប់មួយថ្ងៃមួយយប់បីបួននាក់ ។

វណ្ណៈ	យួនក៏មានស្លាប់ច្រើនដែលពួកាលហ្នឹង?

ភានៈ	បើនិយាយពីយួនវិញខ្ញុំអត់ដឹង អត់ដឹងកាលហ្នឹងព្រោះអីខ្ញុំនៅព្រំប្រទល់ដល់ឆ្នាំ៨១-៨០បានខ្ញុំចូលមកអន្តភាពសមរភូមិដឹងថាវៃគ្នាយ៉ាងម៉េចយ៉ាងម៉ាហ្នឹង ។

វណ្ណៈ	បាទ!ចឹងកាល៨២ពួដាច់ជើងដោយសារសង្គ្រាម?

ភានៈ	បាទ!ដាច់ជើងដោយសារសង្គ្រាម ។

វណ្ណៈ ពូឡើងទៅសមរភូមិ?

ភានៈ បាទ ។

វណ្ណៈ ចឹងកាលនៅជំរំនិងគេដែលយ៉ាងម៉េចបានជាអត់មានចិត្តចង់ទៅក្រៅប្រទេស ទៅស្រុកគេទៅបារាំងអី អាមេរិចអី?

ភានៈ ខ្ញុំអត់មានជំរំខ្ញុំចង់និយាយចេះ ជំរំមានតែជំរំខាងសម្តេចឪប៊ុកតា សឺនសានគាត់នៅជំរំសាយខេណាស់ ។

វណ្ណៈ បាទ ។

ភានៈ ខាងខ្ញុំអត់មានសល់ជំរំទេ បើមានពីណាចង់ស្មគ្រ័ចិត្តចង់និយាយថា លួចរត់ទៅនៅជំរំបណ្តោយ ។

វណ្ណៈ បាទ ។

ភានៈ គេអត់មានប្រកាសថាបងប្អូនណាទៅជំរំឲ្យទៅអត់មានទេ ។

វណ្ណៈ ចឹងយើងទៅតាមច្រក៤០០?

ភានៈ អាហ្នឹងយើងចេញទៅដូចថាចង់ទៅលេងចឹង ដូចថាពូទៅលេងទៅលេងសិនស្អែកឡើងឲ្យប្រពន្ធចេញទៅចង់និយាយចឹងទៅនៅហ្នឹងលែងមកវិញបណ្តោយ ដល់ពេលចឹងគេក៏អត់មានទៅតាមយើងអីដែរ ។

វណ្ណៈ ចឹងគេអត់មានហាមឃាត់យើងទេ?

ភានៈ អត់ទេ តែបើឲ្យគេចំហក៏អត់ចំហដែរ ។

វណ្ណៈ ចឹងបើយើងលួចទៅបានទៅៗ?

ភានៈ យើងទៅបានទៅៗ ព្រោះអីបានថាទៅបានព្រោះអ្នកទៅហ្នឹងអត់មានពីណាហៅមកវិញ ។

វណ្ណៈ បាទ!ចឹងហេតុអីបានជាពូមិននៅស្រុកសំឡូតដល់សព្វថ្ងៃហេតុអីបានជាពូមកនៅនេះវិញ?

ភានៈ កាលហ្នឹងយើងក្រោយអ៊ុនតាក់ចេញចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ភានៈ អ៊ុនតាក់ចេញខ្មែរក្រហមពង្រីកទឹកដីដែលគាត់ឃុំគ្រងបានពីមុនមកហ្នឹងណាស់ អគ្គភាពតាំងពីនេះទៅដល់ចឹងកំលាំងនៅថ្មដារាល់ថ្ងៃនេះ ។

វណ្ណៈ បាទ ។

ភានៈ វាខ្សោយវាអត់មិនសូវមានកំលាំង ។

វណ្ណៈ បាទ ។

ភាន:	ចឹងត្រូវយកអ្នកស្ម័គ្រចិត្តយកមកពីសំឡូត ចឹងស្ម័គ្រចិត្តមកពីហ្នឹងមកគេដឹកឡានអីយកមកដាក់ហ្នឹងតែម្តងបានបង្កើតជាទឹកដីរហូតដល់អូរសោមចឹងទៅណាស់ មានចាប់ដៃគ្នាគ។ចឹងទៅចង់និយាយថាពង្រីកទឹកដីដែលយើងកាន់កាប់បានហ្នឹងណាស់ រហូតដល់យើង៩៧បានបោះឆ្នោតនៅនេះ ។

វណ្ណៈ	បាទ ។

ភាន:	ចឹងឆ្នាំ៩៧ចឹងហើយ តាំងពី៩៣មក៩៧បានបោះទៀត ។

វណ្ណៈ	៩៨?

ភាន:	បាទ!៩៨បានបោះ ។

វណ្ណៈ	ចឹងកាលពូមកដល់ទីនេះដំបូងពូមានឃើញផ្លូវមានស្រាប់ចឹងឬមួយយ៉ាងម៉េច?

ភាន:	ផ្លូវនេះទើបផ្លូវពួកយើងចូលទេ បើផ្លូវ៥៦ចាស់នៅខាងនោះបន្តិច តែផ្លូវហ្នឹងមិនមែនផ្លូវឡានខាងក្នុងគេមានបន្ទាយគេរហូតដល់ទៅលើនោះ គេដឹកសម្ភារៈដឹកស្បៀងដឹកអីមនុស្សម្នាកាត់ព្រៃអី«ក៥»កអីណាស់ កាល«ក៥»ដល់ពួកខ្ញុំមកនេះឃើញផ្លូវហ្នឹងមានស្រាប់ហើយ ។

វណ្ណៈ	បាទ ។

ភាន:	មកដល់យើងស្គាល់ថាត្រង់នេះផ្លូវ៥៦ ដូចនេះផ្លូវ៥៦មិនមែនទើបមានឥឡូវទេ មានតាំងពីមុនមកផ្លូវ៥៦ ។

វណ្ណៈ	បាទ!ប៉ុន្តែមិនមែនផ្លូវបើកឡានបានទេ?

ភាន:	បាទ!មិនមែនផ្លូវបើកឡានបានទេ ។

វណ្ណៈ	ខាងក្រោយសុទ្ធតែព្រៃ?

ភាន:	បាទ!សុទ្ធតែព្រៃក្រោយពីយើងលែងត្រូវគ្នាទៅលែងមានឡានអីចេញមកដល់ចឹងវាដុះព្រៃដុះអីយើងឃើញស្នាមហេតុចឹងយើងទៅមក។បងប្អូនខាងហ្នឹងចង់ទៅពោធិសាត់អីដើរ ។

វណ្ណៈ	ចឹងកាលមកដល់ដំបូងមិនដឹងជារស់នៅយ៉ាងម៉េច ទឹកភ្លើងគ្មានអីក៏គ្មាន?

ភាន:	គ្មានទេ ។

វណ្ណៈ	ចឹងដំបូងមានអារម្មណ៍យ៉ាងម៉េចដែលពូ?

ភាន:	កាលហ្នឹងដូចជាអត់មានអារម្មណ៍ថា យ៉ាងម៉េចម៉ាទេ មកជាអន្តភាពចឹងមកនៅ ។

វណ្ណៈ	តែយើងមិនបាននៅជិតគ្នាណាមានផ្ទះនេះមួយផ្ទះនោះមួយស្ងាត់ឈឹងមានអារម្មណ៍ខ្លាចទេ?

ភាន:	កាលហ្នឹងយើងមកនៅ នៅជុំគ្នាអត់ទាន់មានបំបែកគ្នាទេ ។

វណ្ណៈ	ចឹងអត់មានបំបែកទេ?

ភានៈ	បាទ! នៅហ្នឹងវាមានថាដូចជាមេនៅក្នុងហ្នឹង គាត់មានគ្រឿងចក្រមានឡានមានអាត្រាក់មានប្រេងអីហ្នឹងចេះតែសុំចែកគ្នាដុត ។

វណ្ណៈ	ចឹងក្រោយមកទៀតប្រជាជនយើងមានគ្រោះថ្នាក់ដោយសារយើងកាប់ព្រៃកាប់អីត្រូវមីនបន្តបន្ទាប់ទៀតទេឬក៏យកយ៉ាងម៉េច?

ភានៈ	ដូចជាមានមួយៗទេ អត់មានច្រើនទេ ។

វណ្ណៈ	ចឹងមានអង្គការខាងស៊ីម៉ាកចុះមកជួយដោះដែលអត់?

ភានៈ	កាលហ្នឹងមានស៊ីម៉ាកចូលមកកាលឆ្នាំ៩៨ហើយទេ ។

វណ្ណៈ	ចឹងមានចូលមកជួយដោះដែរ?

ភានៈ	បាទ ។

វណ្ណៈ	ចឹងកាលពូចូលមកដល់ដំបូងមានសត្វព្រៃច្រើនដែរ?

ភានៈ	សត្វព្រៃមានច្រើនណាស់ សឹងថាមិនហ៊ានដើរ ។

វណ្ណៈ	ដំរីមានទេ?

ភានៈ	ដំរីបានឃើញតែដានទេ ។

វណ្ណៈ	ខ្ញុំឮគេថានៅខាងអូរសោមមានច្រើន?

ភានៈ	ហ្នឹងហើយខាងអូរសោមមាននៅដល់សព្វថ្ងៃនេះនៅ តែតំបន់នេះអស់ហើយ ។

វណ្ណៈ	តែតំបន់នេះមានជ្រូកព្រៃមានឈ្លូស?

ភានៈ	មាន និយាយអីជ្រូកព្រៃនៅខាងក្រោយផ្ទះនេះម៉ាគគោក“ អ្នកជិតនិយាយខ្ញុំនិយាយកាត់ប្រសាសន៍គាត់ ។

វណ្ណៈ	បាទ ។

ភានៈ	តំបន់ហ្នឹងកាលឆ្នាំ៨៨-៨៩ហ្នឹងមាន តែឥឡូវអស់ហើយ ខ្លាធំក៏អស់ដែរ ។

វណ្ណៈ	បាទ ។

ភានៈ	“អ្នកជិតនិយាយ” ព្រោះវាទៅឡើងភ្នំសាកុះនោះ ។

វណ្ណៈ	បាទ ។

ភានៈ	យើងមិនថាអស់ទេ ថាមានតំបន់យើងវាអត់មាន ពីមុនឃើញដានតែម្តង ។

វណ្ណៈ	ចឹងពូយើងប្រៀបធៀបមើលថា កាលសម័យតស៊ូមកដល់ឥឡូវពូគិតថា តើនៅសម័យតស៊ូពូរស់នៅស្រួលជាងឬក៏សម័យនេះពូរស់នៅស្រួលជាង?

ភានៈ	ពាក្យថា តស៊ូមួយម៉ាត់អត់មានស្រួលទេ អត់មានស្រួលចឹងតែម្តង ។

វណ្ណៈ បាទ ។

ភានៈ ព្រោះយើងគិតថាមិនស្រួលយ៉ាងម៉េច ព្រោះអីអត់មានសិទ្ធសេរីភាព ថានៅណាក៏ទៅៗតែមិនបានមកជួបបងប្អូននៅនេះ មានបានណាដូចឥឡូវទេណាស់ ។

វណ្ណៈ បាទ ។

ភានៈ រស់នៅវាខុសគ្នាឆ្ងាយណាស់' បើនិយាយទៅខុសគ្នាឆ្ងាយណាស់ ។

វណ្ណៈ ចឹងមកដល់ឥឡូវពូបានទៅលេងស្រុកកំណើតពូប៉ុន្មានដងដែរ?

ភានៈ ខ្ញុំបានទៅលេងបីដងហើយ ។

វណ្ណៈ ចឹងមានចិត្តចង់ទៅរស់នៅស្រុកកំណើតវិញឬមួយពូមានចិត្តដាក់ខ្លួនមកនៅនេះ?

ភានៈ ដាក់ខ្លួននៅនេះរហូតហើយមិនទៅណាទេ ។

វណ្ណៈ ចឹងបងប្អូនពូអីមានមករស់នៅនេះដែលឬមិនមានទេ?

ភានៈ អត់ទេ នៅស្រុកនោះអត់មានមកនៅទីនេះទេ បងប្អូនខ្ញុំមានតែបីនាក់ដូចថ្មចគ្រានចឹងឥឡូវនេះ ។

វណ្ណៈ បាទ ។

ភានៈ ខ្ញុំនៅនេះប្អូនខ្ញុំអាពៅនៅស្រុកកោះសូទិនហ្នឹង បងខ្ញុំបង្អស់នៅគាកែវ ស្រុកគីរីវង្ស ។

វណ្ណៈ បាទ ។

ភានៈ បីនាក់ ។

វណ្ណៈ ចឹងនៅពេលចូលឆ្នាំអីយើងណាត់ជួបគ្នាផ្ទះឪពុកម្ដាយ?

ភានៈ បាទ!និយាយថា ឥឡូវហ្នឹងវាស្រួលវាមានអាត្រចៀកទិព្វទៅណាមកណាអីកោះហៅគ្នាមកជុំបានចឹងទៅ និយាយកាត់ចុះកាលពី៩២ប្អូនខ្ញុំមកលេងនៅសំឡូតហ្នឹង ។

វណ្ណៈ បាទ ។

ភានៈ ដើរតាមផ្លូវមួយអាទិត្យបានមកដល់ខ្ញុំ ហើយផ្ដាំគេចុះឡើងគេចេញចូលបានតែតាមផ្លូវវាមានប្រទ្រុះប្រទះគ្នាបន្តិច ។

វណ្ណៈ បាទ ។

ភានៈ ប្រាប់ឲ្យមកៗដល់ចឹងបានចូល៩៧នេះ ។

វណ្ណៈ បាទ ។

ភានៈ ៩៧យើងត្រូវគ្នាមួយសារទៀតមិនចឹង ។

វណ្ណៈ បាទ ។

ភានៈ ហើយមានប្រទ្រុះប្រទះគ្នាមួយសារទៀត ។

វណ្ណៈ បាទ ។

ភានៈ តែមុនពេលប្រទ្រុះប្រទះគ្នាសម្តេចឲ្យកងទ័ពមកចាប់ដៃយើងយកកាំភ្លើងយកអីមកមានយន្តហោះអីមកចឹង ។

វណ្ណៈ បាទ ។

ភានៈ ហើយដល់ចឹងសុំមេយើងកាលហ្នឹងមានគឹម ពៅ ។

វណ្ណៈ បាទ!ចឹងនៅខាងនេះប្រធានកងពលមានគឹម ពៅ?

ភានៈ គឹម ពៅហើយសុំគាត់ទៅ គាត់ទំនាក់ទំនងខាងយន្តហោះហ្នឹងបានជិះយន្តហោះចុះពោធិចិនតុងទៅលេងស្រុក ។

វណ្ណៈ ចឹងពូបានជិះដែរ?

ភានៈ ជិះយន្តហោះទៅលេងស្រុក ។

វណ្ណៈ យ៉ាងម៉េចបានជាពូបានជិះ?

ភានៈ សុំមេថាទៅលេងស្រុកចឹងគាត់ឲ្យទៅ ។

វណ្ណៈ ជិះយន្តហោះសម្តេចហ្នឹង?

ភានៈ បាទ!អត់ទេ ថាយន្តហោះគាត់ហើយព្រោះអីភ្នាក់ងារគាត់ដឹកអង្ករស្បៀងមកយើងហ្នឹង ។

វណ្ណៈ អ! ។

ភានៈ ដល់ហើយសុំគេជិះយកទៅដាក់ពោធិចិនតុងហ្នឹង មានសាហ៊ុយជិះឡានទៅលេងស្រុកតាមរយៈចឹងទៅ ។

វណ្ណៈ ឆ្នាំណា៩៧ហ្នឹង?

ភានៈ បាទ!៩៧ចឹងបានមកពីលេងស្រុកវិញបានយើងប្រទ្រុះប្រទះមួយសារទៀត មេហ្នឹងដូចថាខ្វែងគំនិតគ្នាយ៉ាងម៉េចខ្លះទៅកើតខ្លះទៅលិចមួយសារទៀតមួយឆ្នាំប៉ុន្មានខែនេះទៀតដល់៩៩យើងឡើងមកនៅនេះដាប់រហូតបណ្តោយ ។

វណ្ណៈ ចឹងគឹម ពៅរាល់ថ្ងៃនេះគាត់នៅរស់ដែរ?

ភានៈ នៅតើគាត់នៅ ។

វណ្ណៈ ឥឡូវគាត់ធ្វើធំដែរ?

ភានៈ គាត់ធ្វើធំដែរ គាត់ដឹងថាទៅជួបសម្តេចមានផ្កាយមានសក្តិណា ។

វណ្ណៈ ពូខ្ញុំសួរតែបន្តិចទៀតទេ ចឹងរាល់ថ្ងៃនេះពូមានដឹងរឿងកាត់ទោសអីទេ មានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

ភានៈ ដឹងថាគេផ្សាយអីតែមិនដឹងថា គេកាត់ទោសអីយ៉ាងម៉េចខ្ញុំមិនសូវដឹងព្រោះនៅឆ្ងាយពីនេះទៅភ្នំពេញឆ្ងាយណាស់ ។

វណ្ណៈ បាទ ។

ភានៈ គ្រាន់តែបានដឹងដំណឹងតាមវិទ្យុអីគេផ្សាយចឹងទៅ ។

វណ្ណៈ ចឹងពូយ៉ាងម៉េចចំពោះការកាត់ទោសតុលាការហ្នឹង ការកាត់ទោសខ្មែរក្រហមហ្នឹងចឹងពូយល់យ៉ាងម៉េចដែរ ចំពោះអារម្មណ៍ពូវិញ?

ភានៈ ចំពោះអារម្មណ៍ខ្ញុំថាបើសិនជាយើងមិនកាត់ទោស អ្នកក្រោយៗនៅមានធ្វើតាមហ្នឹងទៀត ។

វណ្ណៈ បាទ ។

ភានៈ ដល់កាត់ទោសអ្នកក្រោយគេខ្លាចគេហ្នឹងរអាលអត់មានកាប់សម្លាប់ចឹងតទៅទៀតទេ ចង់និយាយថាមិនមានបន្តហេតុអីណាណែទៀត ។

វណ្ណៈ ចឹងដើម្បីឲ្យអ្នកក្រោយធ្វើល្អ?

ភានៈ បាទ! បើសិនជាមនុស្សរួមគ្នាធ្វើល្អហើយ ចុះអាម្នាក់ហ្នឹងទៅធ្វើចឹងទៀតចង់និយាយចឹងណាស់ ។

វណ្ណៈ បាទ ។

ភានៈ ឥឡូវថា កើតមានហេតុការណ៍អីមួយសកលលោកគេគៀបសង្កត់យើងជាក់ស្តែងដូចយើងរាល់ថ្ងៃមិនថាចឹង ។

វណ្ណៈ ចឹងពូជឿជាក់ថា ឥឡូវខ្មែរយើងរួបរួមគ្នាហើយណាស់ ពូជឿថាមានអ្នកនយោបាយណាមកញុសញង់ឲ្យខ្មែរវ៉ៃខ្មែរទៀតពូជឿថា សង្គ្រាមនិងអាចកើតមានម្តងទៀតទេ?

ភានៈ បើថាមានក៏មានតិចតួចព្រោះអីកើតភ្លាមដូចខ្ញុំនិយាយមិញហ្នឹងណាស់ សកលលោកឬថាអ្នកដែលល្អក្នុងស្រុកយើងគេរួមដៃគ្នាកំចាត់អាម្នាក់និងហើយកុំឲ្យអាម្នាក់ហ្នឹងមានទេ ។

វណ្ណៈ បាទ ។

ភានៈ បើមាន មានហេតុការណ៍បន្តិចបន្តួចកន្ទូម៉ោងមួយម៉ោងយ៉ាងយូរមួយថ្ងៃមួយយប់ចឹងចុះ ។

វណ្ណៈ បាទ ។

ភានៈ ក្រៅពីហ្នឹងលែងមានហើយ ។

វណ្ណៈ ចឹងខ្មែរសម្លាប់ខ្មែរលែងមានហើយ?

ភានៈ បាទ!លែងមានហើយខ្ញុំជឿថាលែងមានហើយ ។

វណ្ណៈ ពូជឿជាក់ថាចឹងតែម្តង?

ភានៈ បាទ ។

វណ្ណៈ តែជាមួយបរទេសអាចមានទៀត?

ភានៈ ទេ ជាមួយបរទេសមើលមិនឃើញទេ "អ្នកជិតនិយាយ បើខ្មែរនិងខ្មែរលែងវ៉ៃហើយបើជាមួយបរទេសមាន បើខ្មែរនិងខ្មែរខ្ញុំធានាថាលែងតែម្តង" ។

វណ្ណៈ បាទ ។

ភានៈ អ្នកជិតនិយាយថា "ពីមុនខ្មែរយើងល្ងង់ឥឡូវខ្មែរយើងចេះហើយ" ។

វណ្ណៈ មានឡានមានម៉ូតូជិះហើយចាមតែភ្លើចូលព្រៃទៀតតើ?

ភានៈ អ្នកជិតនិយាយថា "ហ្នឹងហើយសើច....ឃើផ្ទះរាប់ខ្នងមានអីទៀត" ។

វណ្ណៈ បាទ ។

ភានៈ បើជាមួយបរទេសទៅទៀតបាន យើងមិនមែនជាមានមោទនភាពខ្លួនយើងពីមុនមកយើងខំរំដោះកសាងបានក្នុងស្រុកយើងបានហូរហែរល្អហើយ ។

វណ្ណៈ បាទ ។

ភានៈ ទៅជាឥឡូវអាបរទេសមកឈ្លានពានចឹងឈឺចាប់ណាស់ ។

វណ្ណៈ បាទ ។

ភានៈ កុំឲ្យមានអាសន្ត្រោមនិងតទៀត ដូចខ្ញុំចឹងបើដាច់ម្នាងទៀតទៅខ្ញុំធ្វើស្អី ហើយកូនចៅខ្ញុំល្អជាឲ្យទៅពិការដូចខ្ញុំចឹង ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយដែលបានផ្តល់បទសម្ភាសឲ្យខាងខ្ញុំ ។

ភានៈ បាទ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូ ។

ភានៈ បាទ ។

**ចប់**